អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# អ្វីដែលប្អូនីកំពុងស្វែងរក



សូមស្កេនQR Code

គំនូរជីវចល

ធនធានបង្រៀន

Written by Keiko Uehara

Illustrated by Lorna Pilkington



បូរីមើលទៅហាក់មិនសប្បាយចិត្តសោះ។

«បាល់ដីមានតម្លៃរបស់ខ្ញុំបានបាត់! តើអ្នកអាចជួយរកវាជាមួយខ្ញុំបានទេ?»

អូ! តើបាល់នៅឯណា? តស់! ស្វែងរកមើលទាំងអស់គ្នា។



តើបូរីទុកបាល់នៅឯណា?

«ខ្ញុំបានទុកវានៅក្នុងប្រអប់ពណ៌ក្រហម»។

តើប្រអប់ពណ៌ក្រហមមួយណា?




តើប៉ូរីបានសរសេរអ្វីនៅលើប្រអប់ពណ៌ក្រហមនោះ?
«ខ្ញុំបានសរសេរលេខ ៣ នៅលើវា»។
តើប្រអប់ពណ៌ក្រហមមួយណាដែលប៉ូរីបានដាក់បាល់?





អូ! ប្រអប់លេខ ៣ នៅទីនេះ។
តើបាល់ដែលប្អូនកំពុងរកមានសញ្ញាសម្គាល់យ៉ាងដូចម្ដេច?
«បាល់មានពណ៌លឿង ហើយមានរូបត្រីកោណពណ៌ខៀវនៅចំកណ្ដាល»។
តើមានបាល់ដូចដែលប្អូនកំពុងស្វែងរកដែរឬទេ?



មិនមានបាល់នៅក្នុងប្រអប់នេះទេ។
តើបូរីបានដាក់បាល់នៅឯណា?
«ប្រហែលជាខ្ញុំបានដាក់វានៅក្រោមគ្រែរបស់ខ្ញុំ»។
តើមានបាល់នៅក្រោមគ្រែដែរឬទេ?





មិនមានបាល់នៅក្រោមគ្រែទេ។
តើបូរីបានដាក់បាល់នៅឯណា?
«ប្រហែលជាខ្ញុំបានដាក់វានៅខាងឆ្វេងទូសៀវភៅ»។
តើមានបាល់នៅខាងឆ្វេងទូសៀវភៅដែរឬទេ?

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



មិនមានបាល់នៅខាងឆ្វេងទូសៀវភៅទេ។
តើបូរីបានដាក់បាល់នៅឯណា?
«ប្រហែលជាខ្ញុំបានដាក់វានៅក្បែរដើមចេក»។
តើមានបាល់នៅក្បែរដើមចេកដែរឬទេ?



«ម៉េវ! ម៉េវ! ម៉េវ!»

នេះជាសំឡេងសត្វឆ្មារបស់បូរី!



«យ៉េ! ឃើញបាល់ដ៏មានតម្លៃរបស់ខ្ញុំវិញហើយ...»។
តើបាល់នៅឯណា?